
ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន រួមគ្នាបង្ការ

ការចិញ្ចឹមកូនប្រកបដោយសុវត្ថិភាព និងសុខភាពល្អនៅក្នុងប្រទេសកូរ៉េ៖ ការណែនាំអំពីជំនួយគាំទ្រ និងការរាយការណ៍អំពីការរំលោភបំពានលើកុមារ

សម្រាប់អ្នកស្នាក់នៅជាជនបរទេសដែលជាមនុស្សពេញវ័យ



នៅក្នុងប្រទេសកូរ៉េ កុមារគ្រប់រូបមានសិទ្ធិក្នុងការលូតលាស់ប្រកបដោយសុវត្ថិភាព។ ឪពុកម្តាយ និងអាណាព្យាបាលមានទំនួលខុសត្រូវដើម្បីការពារ និងចិញ្ចឹមបីបាច់កូនៗ។ រដ្ឋាភិបាល និងសហគមន៍ក្នុងតំបន់ផ្តល់ជូននូវសេវាកម្មជាច្រើនដើម្បីផ្តល់ជំនួយគាំទ្រដល់កុមារ និងក្រុមគ្រួសារ។ ការណែនាំនេះបង្ហាញពីប្រព័ន្ធនានា និងជំនួយគាំទ្រដែលមានសម្រាប់ឪពុកម្តាយ និងអាណាព្យាបាលដែលកំពុងរស់នៅក្នុងប្រទេសកូរ៉េ។

Ministry of Health and Welfare

NCRC National Center for the Rights of the Child

យល់ដឹងអំពីការរំលោភបំពានលើកុមារនៅក្នុងប្រទេសកូរ៉េ៖ និយមន័យ និងប្រភេទ

កុមារគ្រប់រូបមានសិទ្ធិក្នុងការលូតលាស់ប្រកបដោយសុវត្ថិភាព រួចផុតពីការបំពាន ការមិនអើពើ និងអំពើហិង្សា។ របៀបនៃការចិញ្ចឹមបីបាច់មានលក្ខណៈខុសៗគ្នាទៅតាមប្រទេស និងវប្បធម៌ផ្សេងៗពីគ្នា។ នៅក្នុងប្រទេសកូរ៉េ មិនអនុញ្ញាតឱ្យប្រើប្រាស់ការដាក់ទណ្ឌកម្មលើរាងកាយឡើយ ហើយមានការលើកទឹកចិត្តឱ្យឪពុកម្តាយគោរពកូនៗរបស់ពួកគេ ហើយទំនាក់ទំនងជាមួយពួកគេ។

តើ "ការបំពានលើកុមារ" នៅក្នុងប្រទេសកូរ៉េជាអ្វី?

នៅក្នុងប្រទេសកូរ៉េ ការរំលោភបំពានលើកុមារមានន័យថា សកម្មភាពណាមួយដែលបង្កផលប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍ ឬបង្កឱ្យមានការរងរបួសផ្លូវកាយ ឬផ្លូវចិត្តរបស់កុមារ។ ស្តង់ដានេះក៏អនុវត្តចំពោះឪពុកម្តាយ និងអាណាព្យាបាលផងដែរ។ (មាត្រា 3(7) នៃច្បាប់ស្តីពីសុខុមាលភាពកុមារ)

សកម្មភាពនានាដែលប្រទេសកូរ៉េអាចចាត់ទុកថាជាការរំលោភបំពានលើកុមារ

1. ការបំពានលើរាងកាយ៖



សកម្មភាពដែលមិនមែនចៃដន្យដែលបង្ករបួសស្នាមដល់កុមារ ឬបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍ និងសុខភាពរាងកាយរបស់កុមារ

- ការវាយដំ ឬការខាំកុមារ
- ការគំរាមកំហែងលើការបង្កការឈឺចាប់រាងកាយ ដោយការប្រើប្រាស់វត្ថុ ឬការបង្ខំ
- ការដុតកុមារ ឬធ្វើឱ្យរងរបួសរាងកាយតាមវិធីផ្សេងក្រៅពីនេះ

2. ការបំពានតាមផ្លូវចិត្ត៖



ការប្រមាថដោយពាក្យសំដី ការគំរាមកំហែង ផ្លូវចិត្ត ការបង្ខាំង ឬការរឹតត្បិតសិទ្ធិ ដោយមិនសមហេតុផល ព្រមទាំងការប្រព្រឹត្តចំពោះកុមារប្រកបដោយភាពឃោរឃៅផងដែរ

- ការប្រមាថកុមារ ឬការដៀលត្មះកុមារម្តងហើយម្តងទៀត
- ការរើសអើងទល់នឹងកុមារណាម្នាក់ (ការប្រៀបធៀប ការរើសអើង ឬការបង្ហាញភាពលម្អៀងក្នុងចំណោមបងប្អូនបង្កើត ឬមិត្តភក្តិ)
- សកម្មភាពដែលនាំឱ្យកុមារភ័យខ្លាច ឬមានបញ្ហាថប់បារម្ភ ឧទាហរណ៍ តាមការធ្វើឱ្យកុមារប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ

3.ការរំលោភបំពានផ្លូវភេទ៖



សកម្មភាពផ្លូវភេទណាមួយដែលពាក់ព័ន្ធនឹងកុមារ រួមបញ្ចូលទាំងការបង្ខំឱ្យកុមារធ្វើសកម្មភាពអាសអាភាស ការរៀបចំឱ្យមានសកម្មភាពបែបនេះ និងការបៀតបៀនផ្លូវភេទលើកុមារ

- ការមើលកុមារ ឬការបង្ហាញផ្នែកឯកជនរបស់ខ្លួនទៅកាន់កុមារក្នុងគោលបំណងបំពេញចំណង់ផ្លូវភេទ
- ការរំលោភបំពានផ្លូវភេទលើកុមារ ឬចូលរួមក្នុងសកម្មភាពបំពានសេពសន្ថវៈ ឬធ្វើសកម្មភាពក្នុងន័យបំពានសេពសន្ថវៈលើកុមារ
- ការបង្ខំឱ្យកុមារធ្វើពេស្យាចារ ឬការរៀបចំឱ្យមានការធ្វើពេស្យាចារដែលពាក់ព័ន្ធនឹងកុមារ

4. ការមិនអើពើ៖



ខកខានមិនបានផ្តល់ការការពារ ការថែទាំ ការព្យាបាលតាមវេជ្ជសាស្ត្រ និងការអប់រំជាមូលដ្ឋាន រួមទាំងអាហារ សម្លៀកបំពាក់ និងទីជម្រក ឬការទុកឱ្យកុមារមិនមានការការពារ ដែលបណ្តាលឱ្យជីវិត ឬរាងកាយរបស់កុមារប្រឈមនឹងហានិភ័យ

- ការមិនអនុញ្ញាតឱ្យកុមារចូលសិក្សានៅសាលារៀន ឬរារាំងកុមារមិនឱ្យទទួលបានការអប់រំដោយគ្មានហេតុផលជាក់លាក់ណាមួយ
- ការខកខានមិនបានផ្តល់ឱ្យកុមារនូវអាហារ សម្លៀកបំពាក់ ឬការថែទាំតាមវេជ្ជសាស្ត្រចាំបាច់ណាមួយ
- ការខកខានមិនបានចុះសំបុត្រកំណើតឱ្យកុមារ
- ការទុកឱ្យកុមារនៅផ្ទះតែម្នាក់ឯង ឬស្ថិតក្នុងស្ថានភាពគ្មានការការពារផ្សេងទៀតក្រៅពីនេះ


សញ្ញានានាដែលបង្ហាញថាកុមារត្រូវការជំនួយ

ចំណុចខាងក្រោមនេះអាចជាសញ្ញាដែលបង្ហាញថាកុមារត្រូវការជំនួយ។

- ការរងបួសដែលពិបាកក្នុងការពន្យល់ ឬជាញឹកញាប់មានការរងរបួសនៅកន្លែងដែលជាទូទៅកុមារមិនសមនឹងរងរបួស
- អាកប្បកិរិយាដែលចម្លែកខុសធម្មតាដោយព្យាយាមនៅឆ្ងាយពីអ្នកដទៃ ឬអាកប្បកិរិយាកាចងាយប្រើហិង្សា
- ការអវត្តមានពីសាលារៀនញឹកញាប់ ការរត់ចេញពីផ្ទះ ឬការមកផ្ទះយឺត
- ការឃ្លានអាហារជាប្រចាំ កង្វះអនាម័យផ្ទាល់ខ្លួន ឬសភាពដែលបង្ហាញថាកុមារមានសុខភាពមិនល្អ

ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន៖ វិធីសាស្ត្រដែលប្រទេសកូរ៉េណែនាំ

រដ្ឋាភិបាលកូរ៉េណែនាំឱ្យអនុវត្តការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន ដូច្នេះហើយឪពុកម្តាយ និងកុមារអាចគោរពគ្នាទៅវិញទៅមក ព្រមទាំងអាចលូតលាស់ប្រកបដោយសុខភាពល្អ។ ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមានគឺជាវិធីសាស្ត្រមួយដែលផ្តល់ការគោរពដល់កុមារដូចបុគ្គលឯករាជ្យ ព្រមទាំងជំរុញទំនាក់ទំនងរវាងឪពុកឬម្តាយ-កុមារដែលផ្អែកលើទំនាក់ទំនង និងការយល់ដឹងពីគ្នាទៅវិញទៅមក។ គោលការណ៍នៃការចិញ្ចឹមបីបាច់កូនបែបវិជ្ជមានចំនួន 129 ខាងក្រោមបង្ហាញពីរបៀបយកទ្រឹស្តីនៃគោលការណ៍ទាំងនោះមកអនុវត្ត។



របៀបអនុវត្តការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន៖ គោលការណ៍នៃការចិញ្ចឹមបីបាច់កូនបែបវិជ្ជមានចំនួន 129



1. ដឹងអំពីកូនរបស់អ្នក

កុមារគ្រប់រូបមាននិស្ស័យ និងបុគ្គលិកលក្ខណៈខុសពីគ្នា ហើយមានវឌ្ឍនភាពតាមល្បឿនរៀងខ្លួនរបស់ពួកគេ។ ពិនិត្យមើលកូនរបស់អ្នកឱ្យបានដិតដល់។


(ឧទាហរណ៍) ទុកពេលវេលាឱ្យកុមារដែលមានភាពអៀនខ្មាសច្រើនក្នុងការសម្របខ្លួន



2. ឆ្លុះបញ្ចាំងអំពីខ្លួនអ្នក

គិតអំពីចរិតលក្ខណៈផ្ទាល់ខ្លួនរបស់អ្នកក្នុងនាមជាឪពុកឬម្តាយ និងចំណុចអ្វីខ្លះដែលអ្នកអាចកែលម្អបាន។

(ឧទាហរណ៍) ពិនិត្យមើលអារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកមុនពេលខឹងសម្បានៅពេលកុមារប្រព្រឹត្តកំហុសណាមួយ



3. ផ្លាស់ប្តូរទស្សនៈរបស់អ្នក

សាកសួរថាតើអាកប្បកិរិយាដែលអ្នកយល់ឃើញថាជាបញ្ហាពិតជាត្រូវការការកែតម្រូវដែរឬអត់។

(ឧទាហរណ៍) យល់ដឹងអំពីសំណួរដែលសួរញឹកញាប់របស់កូនអ្នកគឺជាភាពចង់ដឹងចង់ឃើញ



4. លូតលាស់រួមគ្នា

ផ្លាស់ប្តូរតួនាទីរបស់អ្នកក្នុងនាមជាឪពុកម្តាយខណៈពេលដែលកូនរបស់អ្នកលូតលាស់។


(ឧទាហរណ៍) ផ្តល់ឱកាសឱ្យកូនរបស់អ្នកក្នុងការរៀបចំ និងជ្រើសជម្រើសសម្រាប់ខ្លួនពួកគេខណៈពេលពួកគេលូតលាស់



5. ផ្តល់ការយកចិត្តទុកដាក់ឱ្យបានពេញលេញ

នៅពេលដែលអ្នកនៅជាមួយកូនរបស់អ្នក សូមផ្តោតតែលើកូនរបស់អ្នកប៉ុណ្ណោះ។

(ឧទាហរណ៍) ដាក់ទូរស័ព្ទចុះនៅពេលអ្នកជជែកជាមួយកូនរបស់អ្នក



6. ស្តាប់ និងយល់ដឹងពីអារម្មណ៍របស់អ្នកដទៃ

ស្តាប់ដោយយកចិត្តទុកដាក់នៅពេលកុមាររបស់អ្នកបង្ហាញមតិផ្ទាល់ខ្លួនពួកគេ និងចែករំលែកអំពីអារម្មណ៍របស់ពួកគេ។

(ឧទាហរណ៍) ស្តាប់ឱ្យបានគ្រប់ជ្រុងជ្រោយចំពោះកុមារដែលមានជម្លោះជាមួយមិត្តភក្តិ និងការចែករំលែកអារម្មណ៍ក្រៀមក្រំរបស់ពួកគេ



7. ភាពជាប់លាប់

កំណត់ការសន្យា និងវិធានដែលកូនរបស់អ្នកអាចព្រមព្រៀង ហើយអនុវត្តការសន្យា និងវិធានទាំងនោះឱ្យបានជាប់លាប់។

(ឧទាហរណ៍) ប្រកាន់ភ្ជាប់នូវពេលចូលគេងដែលអ្នកបានកំណត់រួមគ្នា



8. ទទួលកំហុសរបស់អ្នក

ទទួលស្គាល់ថាឪពុកម្តាយអាចធ្វើខុសដូចគ្នាដែរ ហើយសុំអភ័យទោស។

(ឧទាហរណ៍) ទទួលកំហុសរបស់អ្នក ហើយអភ័យទោសមុនប្រសិនបើអ្នកមិនអាចគ្រប់គ្រងអារម្មណ៍របស់អ្នកបាន




9. ចិញ្ចឹមបីបាច់កូនរបស់អ្នករួមគ្នា

ការចិញ្ចឹមបីបាច់កូនមិនមែនជាទំនួលខុសត្រូវរបស់ឪពុកម្តាយតែឯងឡើយ។ ស្នើសុំឱ្យមនុស្សជុំវិញអ្នក ឬអ្នកជំនាញសម្រាប់ជំនួយនៅពេលអ្នកត្រូវការជំនួយ។

(ឧទាហរណ៍) ទទួលបានជំនួយពីអ្នកជំនាញ ដូចជាមជ្ឈមណ្ឌលជំនួយសម្រាប់ការថែទាំកុមារ នៅពេលការចិញ្ចឹមបីបាច់កូនមានការលំបាក

តើនរណាជាអ្នកការពារសុវត្ថិភាពរបស់កុមារនៅក្នុងប្រទេសកូរ៉េ?




នៅក្នុងប្រទេសកូរ៉េ ក្រុមគ្រួសារ សាលារៀន សមាគមន៍ក្នុងមូលដ្ឋាន និងរដ្ឋាភិបាលការពារសុវត្ថិភាពរបស់កុមាររួមគ្នា។

បុគ្គលដែលមើលថែទាំសុវត្ថិភាពរបស់កុមារ៖ “អ្នករាយការណ៍ដែលមានកាតព្វកិច្ច”


- គ្រូបង្រៀន បុគ្គលិកនៅមជ្ឈមណ្ឌលថែទាំកុមារ និងមត្តេយ្យសិក្សា អ្នកជំនាញវេជ្ជសាស្ត្រ និងបុគ្គលផ្សេងទៀតដែលជួបកុមារជាញឹកញាប់ និងពិនិត្យតាមដានការលូតលាស់ និងសុខភាពរបស់ពួកគេ។ ពួកគេអាចស្នើសុំជំនួយពីអាជ្ញាធរពាក់ព័ន្ធ (112) ប្រសិនកុមារស្ថិតក្នុងគ្រោះថ្នាក់ ឬមានការសង្ស័យថាមានការរំលោភបំពាន។

- ប្រព័ន្ធនេះបង្កើតឡើងដើម្បីពិនិត្យតាមដានសុវត្ថិភាពរបស់កុមារ និងផ្តល់ជំនួយគាំទ្រតម្រូវការគ្រួសារ មិនមែនដើម្បីដាក់ទណ្ឌកម្មលើឪពុកម្តាយឡើយ។
  ※ មាត្រា 10(2) នៃច្បាប់ស្តីពីការដាក់ទណ្ឌកម្មចំពោះការរំលោភបំពានលើកុមារ។ ច្បាប់នេះអនុវត្តចំពោះប្រភេទការងារចំនួន 27 ដែលការពារកុមារ។



ការការពារបុគ្គលដែលមើលថែទាំកុមារ៖ “ការការពារបុគ្គលដែលរាយការណ៍អំពីការរំលោភបំពានលើកុមារ”





នៅក្នុងប្រទេសកូរ៉េ ច្បាប់នេះការពារព័ត៌មានផ្ទាល់ខ្លួនអំពីបុគ្គលណាម្នាក់ដែលរាយការណ៍អំពីការរំលោភបំពានលើកុមារ ឬស្នើសុំការប្រឹក្សាយោបល់។

គ្មាននរណាម្នាក់អាចប្រាប់ ឬបង្ហាញដល់អ្នកផ្សេងទៀតនូវព័ត៌មានកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នករាយការណ៍ ឬព័ត៌មានពិតណាមួយដែលនឹងបង្ហាញថាតើនរណាជាអ្នករាយការណ៍។ គ្មាននរណាម្នាក់អាចប្រព្រឹត្តចំពោះមិនអំណោយផលសម្រាប់ការរាយការណ៍នេះឡើយ។ ជនណាម្នាក់ដែលបំពានវិធានទាំងនេះអាចត្រូវរងការដាក់ទណ្ឌកម្ម។
※ មាត្រា 10(3) និង 10-2 អំពីច្បាប់ស្តីពីការដាក់ទណ្ឌកម្មចំពោះការរំលោភបំពានលើកុមារ



តើមានអ្វីកើតឡើង នៅពេលដែលមានការសង្ស័យអំពីការរំលោភបំពានលើកុមារ?

ប្រព័ន្ធការពារកុមាររបស់ប្រទេសកូរ៉េបង្កើតឡើងដើម្បីពិនិត្យតាមដានសុវត្ថិភាពរបស់កុមារ និងផ្តល់ជំនួយគាំទ្រតម្រូវការគ្រួសារ មិនមែនដើម្បីដាក់ទណ្ឌកម្មលើឪពុកម្តាយ ឬអាណាព្យាបាលឡើយ។

នីតិវិធីឆ្លើយតបចំពោះការរំលោភបំពានលើកុមារ



1. ទទួលបានរបាយការណ៍ ឬការប្រឹក្សាយោបល់

ទទួលបានការស្នើសុំរបាយការណ៍ និងការប្រឹក្សាយោបល់តាមខ្សែទូរសព្ទសម្រាប់ការរាយការណ៍បាន 24-ម៉ោង (112)។

2. ការស៊ើបអង្កេត និងការពិនិត្យសុវត្ថិភាព

ប៉ូលិស និងមន្ត្រីទទួលបន្ទុកឆ្លើយតបទល់នឹងការរំលោភបំពានកុមារ (មន្ត្រីរដ្ឋាភិបាលតាមមូលដ្ឋានដែលមានទំនួលខុសត្រូវចំពោះករណីនៃការរំលោភបំពានលើកុមារ) ចុះពិនិត្យរួមគ្នាដើម្បីពិនិត្យមើលសុវត្ថិភាពរបស់កុមារ ហើយប្រមូលព័ត៌មានដែលចាំបាច់។





3. ការវាយតម្លៃករណី

លទ្ធផលនៃការស៊ើបអង្កេតនេះកំណត់ថាតើកុមាររូបនេះត្រូវការការការពារឬអត់។

4. ការការពារ និងជំនួយគាំទ្រ

- កុមាររូបនេះទទួលបានសេវាកម្មនានាដូចជាការការពារ ការថែទាំវេជ្ជសាស្ត្រ ការប្រឹក្សាយោបល់ និងការព្យាបាលផ្លូវចិត្តដែលចាំបាច់។
- ក្រុមគ្រួសារ និងអាណាព្យាបាលក៏អាចទទួលបានសេវាសុខុមាលភាព ដូចជាការប្រឹក្សាយោបល់ ការអប់រំ និងការព្យាបាលផ្លូវចិត្ត។






5. ការគ្រប់គ្រងករណីកំពុងបន្ត

ជំនួយគាំទ្របន្តផ្តល់ជូនដើម្បីឱ្យកុមារ និងគ្រួសារ (ឬអាណាព្យាបាល) អាចបន្តការរស់នៅប្រកបដោយសុវត្ថិភាព និងមានសុខភាពល្អ។

វិធីរាយការណ៍អំពើរំលោភបំពានលើកុមារ



អ្នកអាចស្នើសុំជំនួយនៅពេលណាក៏បាន ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសុវត្ថិភាពកូនរបស់អ្នក ឬកំពុងជួបប្រទះការលំបាកក្នុងការចិញ្ចឹមបីបាច់កូន។

ការរាយការណ៍ និងការប្រឹក្សាយោបល់នៅពេលអ្នកកំពុងមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់កុមារ



ប៉ូលិស 112

ការស៊ើបអង្កេត និងការរាយការណ៍អំពីការរំលោភបំពានលើកុមារ

មជ្ឈមណ្ឌលហៅទូរសព្ទរបស់ក្រសួងសុខាភិបាល និងសុខុមាលភាព 129

ការប្រឹក្សាយោបល់អំពីការរំលោភបំពានលើកុមារ សូមវាយលេខ 129 ហើយចុចលេខ 6



ការិយាល័យ Si/Gun/Gu (ទីក្រុង ខោនធី ឬស្រុក)

មតិយោបល់ និងការប្រឹក្សាយោបល់លើការរាយការណ៍អំពីការរំលោភបំពានលើកុមារ
ការស៊ើបអង្កេតលើករណីរំលោភបំពានលើកុមារ និងជំនួយគាំទ្រការការពារកុមារ។



ទីភ្នាក់ងារការពារកុមារ

ការការពារ និងការប្រឹក្សាយោបល់លើជំនួយគាំទ្រសម្រាប់កុមារដែលជាជនរងគ្រោះ
ពីអំពើរំលោភបំពាន និងក្រុមគ្រួសាររបស់ពួកគេ

ទីភ្នាក់ងារសម្រាប់ការតស៊ូមតិអំពីជនមានពិការភាព 1644-8295

ការប្រឹក្សាយោបល់ ការស៊ើបអង្កេត និងជំនួយគាំទ្រសម្រាប់ការការពារកុមារដែលមានពិការភាពដែលរងការរំលោភបំពាន

មជ្ឈមណ្ឌលហៅទូរសព្ទ Danuri 1577-1366

ការប្រឹក្សាយោបល់ ការបកស្រាយផ្ទាល់មាត់ និងជំនួយគាំទ្រសម្រាប់ការការពារក្រុមគ្រួសារដែលមានវប្បធម៌ចម្រុះ
ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពាន

※ អ្នកអាចរាយការណ៍បើទោះបីជាអ្នកមិនដឹងអំពីព័ត៌មានលម្អិតពិតប្រាកដអំពីកុមារ ឬជនដែលសង្ស័យថាបានប្រព្រឹត្តសកម្មភាពរំលោភបំពាន។

ព័ត៌មានអំពីស្ថាប័នពាក់ព័ន្ធ

ស្ថាប័នផ្តល់ជំនួយគាំទ្រសម្រាប់ឪពុកម្តាយ និងក្រុមគ្រួសារ



1 ស្ថាប័នផ្តល់ជំនួយគាំទ្រតាមអនឡាញ

⊕ មជ្ឈមណ្ឌលជាតិសម្រាប់សិទ្ធិកុមា
(National Center for the Rights of the Child) (02-6454-8500, www.ncrc.or.kr)
ផ្តល់ជូននូវកម្មវិធីសុខុមាលភាពសម្រាប់កុមារ និងការគាំទ្រសម្រាប់ការអភិវឌ្ឍគោលការណ៍រួមបញ្ចូលគ្នា

⊕ អាយសារ៉ង់ (i-Sarang) (www.childcare.go.kr)
ការសម្រាលកូន ការថែទាំកូន និងការចុះឈ្មោះចូលមជ្ឈមណ្ឌលថែទាំកុមារ ឬមត្តេយ្យសិក្សា បូករួមទាំងសេវាប្រឹក្សាយោបល់ពី អ្នកជំនាញ

⊕ កម្មវិធីឪពុកម្តាយល្អ កូនៗរីករាយ (Good Parents, Happy Children) (www.mogef.go.kr/kps/main.do)
ការបង្រៀនអប់រំឪពុកឬម្តាយ ព័ត៌មានអំពីការចិញ្ចឹមបីបាច់កូនតាមអាយុ និងធនធាននានាសម្រាប់ចិញ្ចឹមកូន

⊕ មាតាបិតា On នូរី (Parents On Nuri) (www.parents.go.kr)
វេទិកាអំពីការអប់រំកូន រួមទាំងការរៀនសូត្រដោយខ្លួនឯង អាជីព និងការចូលរៀន ភាពច្នៃប្រឌិត និងការអប់រំចរិតលក្ខណៈ

⊕ បុកជីរ៉ូ (Bokjiro) (www.bokjiro.go.kr)
ព័ត៌មានអំពីកម្មវិធីសុខុមាលភាពតាមដំណាក់កាលនៃជីវិត និងការដាក់ពាក្យស្នើសុំសេវាកម្ម

⊕ មជ្ឈមណ្ឌលផ្តល់ការប្រឹក្សាអំពីសុខភាព និងសុខុមាលភាព
(Health and Welfare Counseling Center) (129, www.129.go.kr)
ការប្រឹក្សាយោបល់ និងការណែនាំអំពីសេវាឆ្លើយតបវិបត្តិសម្រាប់ការគាំទ្រសុខុមាលភាពបន្ទាន់ សុខភាពផ្លូវចិត្ត និងការរំលោភបំពានលើកុមារ



2 ស្ថាប័នគាំទ្រអហ្វឡាញ

⊕ មជ្ឈមណ្ឌលគាំទ្រនៃការិយាកណ្តាលសម្រាប់ការថែទាំកុមារ
(Central Support Center for Childcare) (1577-0756, https://central.childcare.go.kr)
សេវាចិញ្ចឹមបីបាច់កូន រួមទាំងការអប់រំ និងការប្រឹក្សាដល់ឪពុកឬម្តាយ ការជួលប្រដាប់ក្មេងលេង និងសៀវភៅ និងបន្ទប់លេង

⊕ មជ្ឈមណ្ឌលសម្រាប់គ្រួសារ (Family Center) (1577-9337, www.familynet.or.kr)
កម្មវិធីថែទាំ រួមទាំងការអប់រំ និងការប្រឹក្សាយោបល់អំពីគ្រួសារ ការកសាងសមត្ថភាពគ្រួសារ ការចែករំលែកការថែទាំគ្រួសារ មជ្ឈមណ្ឌលចិញ្ចឹមបីបាច់កូនរួមគ្នា និងសេវាកម្មគាំទ្រការថែទាំកុមារ

⊕ វិបផតថលគាំទ្រគ្រួសារពហុវប្បធម៌ដានូរី
(Multicultural Family Support Portal Danuri) (1577-1366, www.liveinkorea.kr)
ការប្រឹក្សាយោបល់សម្រាប់គ្រួសារដែលមានវប្បធម៌ចម្រុះ និងការណែនាំអំពីកម្មវិធីគាំទ្រ



ជាចុងក្រោយ ជូនចំពោះឪពុកម្តាយដែលចិញ្ចឹមកូននៅប្រទេសកូរ៉េ

ប្រទេសកូរ៉េផ្តល់អាទិភាពដល់សុវត្ថិភាព និងសិទ្ធិរបស់កុមារជាចម្បង ហើយផ្តល់សេវាកម្មគាំទ្រជាច្រើនដើម្បីឱ្យឪពុកម្តាយ និងក្រុមគ្រួសារអាចចិញ្ចឹមកូនរបស់ពួកគេបានល្អ។ ស្វែងរកជំនួយបានពេលណាក៏បានអំពីសុវត្ថិភាពកូនរបស់អ្នក ឬនៅពេលមានការលំបាកក្នុងការចិញ្ចឹមបីបាច់កូន។ ប្រទេសកូរ៉េធ្វើការជាមួយអ្នក ដើម្បីកូនអ្នក និងគ្រួសារអ្នកធំឡើងដោយមានសុខភាពល្អ និងសុវត្ថិភាព។